វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី៣១ ខែសីហា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ភ្នំពេញធ្វើជាម្ចាស់នៃការតាំងពិពណ៌អចលនទ្រព្យរបស់អាស៊ាន
- ទំនាក់ទំនងរវាងចិន និងជប៉ុនមានការរីកចម្រើន ស្របពេលដែលប្រទេសទាំងពីរប្រឈមនឹងសម្ពាធពីអាមេរិកដូចគ្នា
- ទំនុកចិត្តរបស់អ្នកប្រើប្រាស់អាមេរិក កើនឡើងខ្ពស់ក្នុងរយៈពេលជិត១៨ឆ្នាំ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ភ្នំពេញធ្វើជាម្ចាស់នៃការតាំងពិពណ៌អចលនទ្រព្យរបស់ អាស៊ាន

ភ្នំពេញថ្មីៗនេះបានធ្វើជាម្ចាស់ផ្ទះប្រារព្ធនូវសន្និបាតប្រចាំឆ្នាំនៃសម្ព័ន្ធបណ្តាញអចលនទ្រព្យអាស៊ាន ASEAN Real Estate Network Alliance ដោយប្រមូលផ្តុំអ្នកជំនាញផ្នែកអចលនទ្រព្យពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន និងពិភពលោក។

កំណើនសេដ្ឋកិច្ច និងប្រជាពលរដ្ឋ បានបង្កើននូវតម្រូវការអាគារស្នាក់នៅ និងសំណង់នៅក្នុងប្រទេសកម្ពុជា ដែលនាំមកនូវការវិនិយោគរហូតដល់ ២៣,១៤ ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ នេះបើយោងតាម លោក ឆាល វ៉ាន់ (Charles Vann) មកពីសមាគមកម្មករសំណង់កម្ពុជា (CCA)។

អ្នកចូលរួមក្នុងសន្និបាតនេះ រួមមាន លោក មី វ៉ាន់ អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុឧស្សាហកម្ម នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកោតសរសើរនូវការរៀបចំព្រឹត្តការណ៍ពិព័ណ៌អន្តរជាតិដ៏ធំនេះ ដែលនឹងជួយដល់ការទាក់ទាញអ្នកវិនិយោគបរទេសមកកម្ពុជា។

### តារាងប្រចាំសប្តាហ៍៖ សន្ទស្សន៍ស្ថានភាពឡជីស្ទិកនៅអាស៊ាន

តារាងសប្តាហ៍នេះបង្ហាញពីការប្រៀបធៀបនូវដំណើរការដឹកជញ្ជូនក្នុងប្រទេសនៃតំបន់អាស៊ាន។ សន្ទស្សន៍នៃដំណើរការការដឹកជញ្ជូន (Logistic Performance Index) ផ្តោតទៅលើគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការដឹកជញ្ជូន ដែលអាចប្រើប្រាស់ជាឧបករណ៍ជួយដល់ប្រទេសនានាក្នុងការកំណត់នូវបញ្ហាប្រឈម និងឱកាស។ ប្រទេសសិង្ហបុរីមានចំណាត់ថ្នាក់ល្អជាងគេ ក្នុងបណ្តា

ប្រទេសទាំងអស់ក្នុងតំបន់អាស៊ាន ក្នុងឆ្នាំ២០១៨។ កម្ពុជា និងមីយ៉ាន់ម៉ាគឺប្រទេសដែលមានចំណាត់ថ្នាក់ទាបបំផុត។ សន្ទស្សន៍នេះក៏បែងចែកជាការពិនិត្យទៅលើការអនុវត្តលើហេដ្ឋារចនាសម្ព័ន្ធ និងពេលវេលាក្នុងការដឹកជញ្ជូនផងដែរ។

### សន្ទស្សន៍ស្ថានភាពឡូជីស្ទិកនៅអាស៊ាន ឆ្នាំ២០១៨




ប្រភព៖ ធនាគារពិភពលោក នៅក្នុងចំណាត់ថ្នាក់សកលលោក ២០១៨

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ទំនាក់ទំនងរវាងចិន និងជប៉ុនមានភាពប្រសើរជាងមុន ស្របពេលដែលប្រទេសទាំងពីរប្រឈមនឹងសម្ពាធពីអាមេរិកដូចគ្នា

យោងតាមព័ត៌មានរបស់Bloomberg រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុរបស់ជប៉ុន លោក តារ៉ូ អាសូ (Taro Aso) នឹងធ្វើទស្សនកិច្ចនៅទីក្រុងប៉េកាំងនៅក្នុងសប្តាហ៍នេះ ដើម្បីពិភាក្សាទៅលើសេដ្ឋកិច្ចទ្វេភាគី។ កិច្ចប្រជុំនេះត្រូវបានរំពឹងថានឹងពង្រឹងសហប្រតិបត្តិការនៅក្នុងផ្នែកមួយចំនួន ជាពិសេសការស្តារ និងការពង្រីករៀបចំការដោះដូររូបិយប័ណ្ណ (currency-swap) ។ ប្រទេសទាំងពីរសង្ឃឹមថា ទំនាក់ទំនងល្អជាងមុននេះ អាចជួយកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីវិធានការការពារពាណិជ្ជកម្មឯកតោភាគីរបស់អាមេរិច។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ទំនុកចិត្តរបស់អ្នកប្រើប្រាស់(Consumer confidence) អាមេរិកកើនឡើងខ្ពស់ក្នុងរយៈពេលជិត១៨ឆ្នាំ

សន្ទស្សន៍ដែលបង្ហាញពីទំនុកចិត្តរបស់អ្នកប្រើប្រាស់ (consumer confidence index) របស់ក្រុមប្រឹក្សាភិបាលសន្និសីទ បានកើនឡើងទៅដល់ ១៣៣,៤ នៅខែសីហា ធៀបនឹងខែកក្កដាត្រឹមតែ ១២៧,៩។ ការកើនឡើងនេះគឺខុសពីការរំពឹងទុក ព្រោះអ្នកសេដ្ឋកិច្ចរំពឹងថានឹងធ្លាក់ចុះមកត្រឹម១២៦,៨។ ជាមួយនឹងការកើនឡើងនេះ សន្ទស្សន៍ទំនុកចិត្តរបស់អ្នកប្រើប្រាស់ បានលោតដល់កម្រិតខ្ពស់បំផុតតាំងពីឆ្នាំ២០០០ (១៣៥,៨)។ ការកើនឡើងនេះនឹងបន្តគាំទ្រដល់ការចំណាយរបស់អ្នកប្រើប្រាស់ នៅក្នុងរយៈពេលខ្លីខាងមុខ។

### ការបញ្ជាទិញទំនិញប្រើប្រាស់បានយូររបស់អាមេរិក ធ្លាក់ចុះជាងការរំពឹងទុក នៅក្នុងខែកក្កដា

នាយកដ្ឋានពាណិជ្ជកម្មសហរដ្ឋអាមេរិក បានរាយការណ៍នៅសប្តាហ៍នេះថា ការបញ្ជាទិញទំនិញប្រើប្រាស់បានយូរ (durable goods) បានធ្លាក់ចុះប្រមាណ ១,៧ ភាគរយនៅក្នុងខែកក្កដា បន្ទាប់ពីកើនឡើង ០,៧ ភាគរយនៅក្នុងខែមិថុនា។ ការថយចុះគួរឱ្យកត់សម្គាល់នៃការបញ្ជាទិញនេះ (ដែលអ្នកសេដ្ឋកិច្ចរំពឹងថានឹងធ្លាក់ចុះត្រឹមតែ ១,២ភាគរយប៉ុណ្ណោះ) មួយភាគធំបណ្តាលមកពីការថយចុះការបញ្ជាទិញឧបករណ៍ដឹកជញ្ជូនប្រមាណ ៥,៣ភាគរយ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

សប្តាហ៍នេះគឺជាសប្តាហ៍អតិផរណា សម្រាប់តំបន់អាស៊ាន ព្រោះលទ្ធផលសម្រាប់ខែសីហាកំពុងតែបោះពុម្ពផ្សាយសម្រាប់ថៃ ឥណ្ឌូនេស៊ី កូរ៉េខាងត្បូង និងហ្វីលីពីន។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងតាមដាននិងស្រាវជ្រាវនៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី០៣ ខែកញ្ញា</u>

- សន្ទស្សន៍ការទិញរបស់អ្នកគ្រប់គ្រងក្នុងវិស័យកម្មន្តសាល (Manufacturing Purchasing Managers' Index) របស់មីយ៉ាន់ម៉ា សម្រាប់ខែសីហា
- សន្ទស្សន៍ការទិញរបស់អ្នកគ្រប់គ្រងក្នុងវិស័យកម្មន្តសាល របស់ហ្វីលីពីន សម្រាប់ខែសីហា
- សន្ទស្សន៍ការទិញរបស់អ្នកគ្រប់គ្រងក្នុងវិស័យកម្មន្តសាល របស់ថៃ សម្រាប់ខែសីហា
- អតិផរណារបស់ថៃ សម្រាប់ខែសីហា
- អតិផរណារបស់ឥណ្ឌូនេស៊ី សម្រាប់ខែសីហា

<u>ថ្ងៃអង្គារ ទី០៤ ខែកញ្ញា</u>

- កំណើនផ.ស.ស. របស់កូរ៉េខាងត្បូង សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៨
- អត្រាអតិផរណារបស់កូរ៉េខាងត្បូង សម្រាប់ខែសីហា
- ការលក់រាយរបស់ថៃ សម្រាប់ខែមិថុនា
- ភាពជឿជាក់ផ្នែកធុរៈកិច្ច របស់ថៃ សម្រាប់ខែសីហា
- ការចំណាយផ្នែកសំណង់នៅអាមេរិច សម្រាប់ខែកក្កដា

<u>ថ្ងៃពុធ ទី០៥ ខែកញ្ញា</u>

- អតិផរណារបស់ហ្វីលីពីន សម្រាប់ខែសីហា
- សមតុល្យពាណិជ្ជកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែកក្កដា
- អតិផរណារបស់តៃវ៉ាន់ សម្រាប់ខែសីហា
- សមតុល្យពាណិជ្ជកម្មរបស់អាមេរិច សម្រាប់ខែកក្កដា

<u>ថ្ងៃព្រហស្បតិ៍ ទី០៦ ខែកញ្ញា</u>

- គណនីចរន្តរបស់កូរ៉េខាងត្បូង សម្រាប់ខែកក្កដា
- ភាពជឿជាក់របស់អ្នកប្រើប្រាស់នៅថៃ សម្រាប់ខែសីហា
- ភាពជឿជាក់របស់អ្នកប្រើប្រាស់នៅឥណ្ឌូនេស៊ី សម្រាប់ខែសីហា

<u>ថ្ងៃសុក្រ ទី០៧ ខែកញ្ញា</u>

- ភាពជឿជាក់របស់អ្នកប្រើប្រាស់នៅហ្វីលីពីន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- ការចំណាយគ្រួសាររបស់ជប៉ុន សម្រាប់ខែកក្កដា
- ទុនបម្រុងសម្រាប់អត្រាប្តូរប្រាក់នៅហ្វីលីពីន សម្រាប់ខែសីហា
- ទុនបម្រុងសម្រាប់អត្រាប្តូរប្រាក់នៅថៃ សម្រាប់ខែសីហា
- សមតុល្យពាណិជ្ជកម្មនៅតៃវ៉ាន់ សម្រាប់ខែសីហា
- ទុនបម្រុងសម្រាប់អត្រាប្តូរប្រាក់នៅសឹង្ហបុរី សម្រាប់ខែសីហា
- ទុនបម្រុងសម្រាប់អត្រាប្តូរប្រាក់នៅឥណ្ឌូនេស៊ី សម្រាប់ខែសីហា
- ប្រាក់បៀវត្ស មិនមែនកសិកម្មនៅអាមេរិក សម្រាប់ខែសីហា
- អត្រាអ្នកគ្មានការងារធ្វើនៅអាមេរិក សម្រាប់ខែសីហា៕

************************